# ចំនាប់អារម្មណ៍របស់ខ្ញុំ

## ដោយ សុខ វិរៈ

## ភ្នំពេញ

ចំនាប់អារម្មណ៍របស់ខ្ញុំបាទ ក្រោយពីបានអានកម្មវិធី **សម្លេងយុត្តិធម៌** អំពីប្រល័យពូជសាសន៍ និង ការអត់ឃ្លានក្នុងរបបខ្មែរក្រហមដែលបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលប្រធានបទសំខាន់ផ្តោតលើការ **អត់ឃ្លាន** ទាំងបួនវគ្គរួចមក ខ្ញុំមានចំនាប់អារម្មណ៍ថា :

ជាដំបូងខ្ញុំបានស្វែងយល់ពីដំណើរការសវនាការសំណុំរឿង ០០២ និង ការវិវឌ្ឍន៍របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និង បានធ្វើអោយខ្ញុំបានស្វែងកាន់តែច្បាស់ថានៅក្នុងរបបខ្មែរក្រហម ការប្រើអំពើហឹង្សាដោយផ្ទាល់មិនមែនជាមូលហេតុតែមួយគត់ នៃ ការស្លាប់របស់ប្រជាជនស្លូតត្រង់រាប់លាននាក់នោះទេ ៨សែននាក់ ទៅ ១លាន៣សែននាក់ ស្លាប់ដោយកត្តាផ្សេងៗដូចជាចាស់ជរា បន្តែភាគច្រើនបានស្លាប់ដោយសារការអត់ឃ្លាន ឬក៏ កង្វះរបបអាហារជាដើមៗ ជាពិសេសចខ្ញុំបានដឹងពត៌មានទូទៅទាក់ទង និងការអត់ឃ្លានក្នុងរបបខ្មែរក្រហម ពីដំណាក់កាលមួយទៅដំណាក់កាលមួយ នៃដើមចមបណ្តាលអោយមានការអត់ឃ្លាននៅក្នុងរបបនោះដូចជា គម្រោងផែនការបួនឆ្នាំ របស់ខ្មែរក្រហមជាការ ពន្លឿនហួសកម្រិតដែលបង្កអោយមានការអត់ឃ្លានកើតឡើងទូទាំងប្រទេសៗ អ្វីដែលមានសារៈសំខាន់ខ្ញុំបានដឹង មូលហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងដែលខ្ញុំមានចម្ងល់ជាយូរមកហើយ និងពត៌មានផ្សេងៗដែលខ្ញុំមិនបានដឹងពីមុនមក ៗ

តាមយោបល់ខ្ញុំបាទមានសំនូមពរចង់អោយ មជ្ឈមណ្ឌលឯកសារកម្ពុជា បន្ថែមម៉ោងក្នុងការផ្សាយ ឬក៏ ថ្ងៃនៃការផ្សាយពីព្រោះវាមានសារៈសំខាន់ណាស់សំរាប់សិស្ស និស្សិត ឬ ប្រជាពលរដ្ឋខ្មែរអោយពួកគាត់បានស្វែងអោយកាន់តែច្បាស់ នៅក្នុងរបបដ៏យោរយៅនោះ ក៏ដូចជាបន្តបង្កើត កម្មវិធី**សម្លេងយុត្តិធម៌** ដែលប្រធានបទផ្តោតសំខាន់លើការ **ធ្វើទារុណកម្ម** ជាដើមដែលនេះជាប្រធានបទដែល សិស្ស និស្សិត ប្រជាពលរដ្ឋខ្មែរក៏ដូចជារូបខ្ញុំផ្ទាល់ចង់ស្វែងយល់បន្ថែមពីការ ធ្វើទារុណកម្មក្នុងរបបនោះព្រៃផ្សៃ និងដោយវិធីយ៉ាងណាខ្លះ ដែលបណ្តាលអោយមានការបង្ហូរឈាមប្រជាជនស្លូតត្រង់អស់រាប់លាននាក់ៗ

ជាចុងក្រោយសូមថ្លែងអំណរគុណដល់ មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានខិតខំស្វែងបង្កើតកម្មវិធីល្អៗ ជាក់ស្តែងដូចជា កម្មវិធី **សម្លេងយុត្តិធម៌** ៗ

## My Personal Reflection[2]

By SoK Virak
Phnom Penh

After listening to 4 episodes of "Voice of Genocide: Justice and the Khmer Rouge Famine program" from the Documentation Center of Cambodia which focused on starvation, I felt that:

First of all, I got to know about the prosecution of Case 002, and the development of the Khmer Rouge Trial. In addition, I got to know more about KR. Violence was not the only root of millions of deaths. Around 0.8 to 1.3 million people died because of old age, starvation, lack of food, and so on. I especially learned about the stages that led to starvation in KR. Particularly, the 4-year-plan led to the high demand of food cultivation which eventually caused starvation in the whole country. Most importantly, I was able to clear my doubts about deportation, and learned more about the information that I had never known.

Personally, I hope DC-Cam can add extra hours or days for the broadcasting because it is very important for students and Khmer people to get a clear view about this cruel regime. Moreover, DC-Cam should design Voice of Justice episodes that focus on other topics such as torture, and so on. This is the topic that students, Khmer people, and I would like to learn about. I am wondering about the methods of torture that took away millions of people's lives.

Finally, I would like to express my appreciation to DC-Cam which always seeks to establish goods programs such as Voice of Justice.

---

[2] Translated by Hing Tetmony; ; edited by Tan Sock Keng